ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ១១១៣៣ សជណ.អក.អត

## សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា ៖ ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្តូរ តម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម ៖

១. ថ្ងៃព្រហស្បតិ៍ទី២៥ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី ៖ (១)តំបន់ភ្លើងលេខ P018 ស្ថិតនៅភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (២) តំបន់ភ្លើងលេខ ប.ត165 ស្ថិតនៅភូមិព្រែកទាល់ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ និង (៣) តំបន់ភ្លើងលេខ P918, P1082, P1083, P1084 ស្ថិតនៅភូមិសំបួរ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

២. ថ្ងៃសុក្រទី២៦ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី ៖ (១)តំបន់ភ្លើងលេខ P018, P322 ស្ថិតនៅភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដំណាក់ធំ៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភូមិត្រពាំងថ្លឹង ភូមិគោកចំបក់ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៣. ថ្ងៃសៅរ៍ទី២៧ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៦ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី ៖ (១)តំបន់ភ្លើងលេខ ប.ត071, PT582 ស្ថិតនៅតាមបណ្តោយផ្លូវលេខ២២៨ ក្នុងសង្កាត់បឹងកេងកង១ ខណ្ឌចំការមន និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃសណ្តែក ភូមិព្រៃល្វា ភូមិព្រៃជីសាក់ ភូមិថ្មគោល ភូមិជ្រៃកោង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤. ថ្ងៃអាទិត្យទី២៨ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី ៖ (១)តំបន់ភ្លើងលេខ ប.ត507 ស្ថិតនៅតាមបណ្តោយផ្លូវលេខ២៧៨ ក្នុងសង្កាត់បឹងកេងកង១ ខណ្ឌចំការមន និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងថ្លឹង ភូមិចោមចៅ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

អគ្គិសនីកម្ពុជា ៖ # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ៖ ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ ៖ (៨៥៥) ២៣ ៤២៦ ០១៨